**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៤៩២ អយក.ប្រក

**ប្រកាស**

ស្តីពី ការបើកសាលាបឋមសិក្សា **កំពង់ព្លៅ**

ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ស្វាយចេក**

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស .រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់តំណាងប្រជាពលរដ្ឋភូមិកំពង់ព្លៅ ឃុំកោះខ្ញែរ ស្រុក សំបូរ ខេត្តក្រចេះ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២ដោយមានចំណារឯកភាពរបស់ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ក្រចេះ** ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**សំរេច**

**ប្រការ១** : បើកសាលាបឋមសិក្សា **កំពង់ព្លៅ** ដែលមានទីតាំងស្ថិតនៅ ភូមិ **កំពង់ព្លៅ** ឃុំ **កោះខ្ញែរ** ស្រុក **សំបូរ** ខេត្ត **ក្រចេះ** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ស្វាយចេក** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **កំពង់ព្លៅ** ត្រូវដឹកនាំដោយ ប្រធានក្រុមមួយរូប ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **ស្វាយចេក** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ក្រចេះ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **សំបូរ** នាយកសាលាបឋមសិក្សា **ស្វាយចេក** ប្រធានក្រុមសាលាបឋមសិក្សា **កំពង់ព្លៅ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

**ឧ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **ក្រចេះ**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា.បស